# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Aug-2012, 13:14
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់លោក អៀង សារី អនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងសម្ភារៈឯកសារដែលអាចនឹងយកមកប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ PHILIP SHORT

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ុរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង ធូ មន្នី

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមវិធាន ៨៧(៤) នៃ វិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") ស្នើសុំដាក់អត្ថបទមួយដែលនិពន្ធដោយលោក Philip Short មានចំណង ជើងថា *Devil's Advocate: There Should be no KR Trial* (*ការតស៊ូមតិរបស់ក្រុមបីសាច៖ មិនគួរ មានតុលាការកាត់ទោសខ្មែរក្រហម*) នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឱកាសបានប្រើ ប្រាស់អត្ថបទនេះក្នុងពេលសួរដេញដោលលោក Short។ សំណើនេះជាការចាំបាច់ដោយសារ អត្ថបទ នេះមានភាពពាក់ព័ន្ធ និងមានតម្លៃជាភស្តុតាង ហើយមេធាវីការពារក្តីចាត់ទុកថា ជាការចាំបាច់ដែលត្រូវ ដាក់អត្ថបទនេះសម្រាប់សួរដេញដោលលោក Short ក៏ប៉ុន្តែនេះអត្ថបទនេះមិនត្រូវបានដាក់នៅចំពោះមុខ អង្គជំនុំជម្រះ ឬមិនទាន់បានចុះលេខឯកសារ E3 នៅឡើយទេ។

## I. ច្បាប់

១. វិធាន ៨៧(១) ចែងថា៖ "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាង ទាំងអស់ត្រូវតែទទួលយក"។

២. វិធាន ៨៧(៣) ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

> អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ ឃើញថា៖
>
> ក-មិនពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា
>
> ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ
>
> គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំ ពិនិត្យភស្តុតាង
>
> ឃ-ច្បាប់មិនអនុញ្ញាត ឬ
>
> ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

៣. វិធាន ៨៧(៤) ចែងថា៖

ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាន នៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។

## II. ឧទ្ធិករណ៍

៤. មេធាវីការពារក្តីស្នើសុំដាក់អត្ថបទមួយដែលនិពន្ធដោយលោក Philip Short មានចំណងជើងថា *Devil's Advocate: There Should be no KR Trial* (*ការតស៊ូមតិរបស់ក្រុមបីសាច៖ មិនគួរមានតុលាការកាត់ទោសខ្មែរក្រហម*) នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំប្រើប្រាស់អត្ថបទនោះនៅពេលសួរដេញដោលលោក Short។ អត្ថបទត្រូវបានសរសេរជាភាសាអង់គ្លេស និងត្រូវបានបកប្រែជាភាសាខ្មែរ និងបារាំង និងបានដាក់ក្នុងឃ្លាំងផ្ទុកឯកសាររួម។ អត្ថបទនេះជាភាសាអង់គ្លេសមានលេខ ERNs 00839943-00839947 ភាសាខ្មែរ ERNs 00842704-00842714 និង ភាសាបារាំង ERNs 00842099-00842105[1]។ អត្ថបទនេះស្របទៅតាមលក្ខខណ្ឌនានាដែលមានចែងក្នុងវិធាន ៨៧(៣)។ អត្ថបទនេះមានភាពពាក់ព័ន្ធ ដោយសារលោក Short ជាអ្នកនិពន្ធ ហើយគាត់បានបង្ហាញពីទស្សនៈរបស់ខ្លួនលើបញ្ហានានា ដែលទាក់ទិននឹងសំណុំរឿង ០០២/០១ ដូចជាចេតនារបស់មេដឹកនាំជាន់ខ្ពស់ទាក់ទិននឹងជនជាតិចាម និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងមន្ទីរ ស-២១។ អត្ថបទនេះមិនជាន់គ្នាជាមួយនឹងសម្ភារៈឯកសារផ្សេងទៀតនៅក្នុងសំណុំរឿងទេ ហើយក៏ពុំមានចេតនាពន្យារកិច្ចដំណើរការនីតិវិធីដែរ។

៥. អត្ថបទនេះអាចទទួលយកបានតាមវិធាន ៨៧(៤)។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុង

---

[1] ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីមានភាពងាយស្រួល យើងខ្ញុំសូមភ្ជាប់អត្ថបទនេះជា ៣ ភាសានៅក្នុងឧបសម្ព័ន្ធ។

កាសែតភ្នំពេញប៉ុស្តិ៍ក្នុងឆ្នាំ ២០០០ តែមេធាវីការពារក្តីទើបតែទទួលបាននាពេលថ្មីៗនេះ។ ទោះបីអត្ថបទនេះមានមុនពេលបើកការជំនុំជម្រះក៏ដោយ ប៉ុន្តែនៅពេលនោះ មេធាវីការពារក្តីពុំបានដឹងពីអត្ថិភាពនៃឯកសារនេះទេ។ ដោយសារការបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយការយកចិត្តទុកយ៉ាងខ្ជាប់ខ្ជួន មេធាវីការពារក្តីបានពិនិត្យសម្ភារៈឯកសារទាំងអស់ ដែលអាចរកបានពាក់ព័ន្ធនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ។ មុនពេលបើកការជំនុំជម្រះក្តី មេធាវីការពារក្តីមិនទាន់បានបញ្ចប់ការងារនេះពាក់ព័ន្ធនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅឡើយទេ។ ជាពិសេសដោយពិចារណាឃើញថា បញ្ជីឈ្មោះសាក្សីមិនទាន់ត្រូវបានសម្រេចស្ថាពរនាពេលនោះ ការងារនេះមិនអាចធ្វើទៅបានទេ។ ជាងនេះទៀត នៅពេលត្រៀមរៀបចំបញ្ជីឯកសាររបស់ខ្លួន ភាគីមិនបានទទួលការជូនដំណឹងថា ពួកគេចាំបាច់ត្រូវបញ្ចូលសម្ភារៈឯកសារថ្មីៗដែលអាចពាក់ព័ន្ធនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលភាគីផ្សេងបានស្នើសុំនោះទេ។ ការពិត មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង បានអះអាងថា៖ "<u>វិសាលភាពនៃកាតព្វកិច្ចក្នុងការដាក់បញ្ជីឯកសារ/វត្ថុតាង</u>[:] អង្គជំនុំជម្រះសូមបញ្ជាក់ថា នៅថ្ងៃទី ១៩ ខែ មេសា ភាគីទាំងអស់មានកាតព្វកិច្ចដាក់*តែ*ឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងសាក្សីដែលខ្លួនស្នើសុំ និងរឿងក្តីដាក់បន្ទុកដល់កូនក្តីរបស់ខ្លួន*ប៉ុណ្ណោះ*។ *ពុំមានកាតព្វកិច្ចដាក់ឯកសារនានាដែលត្រូវបានសន្មតថាពាក់ព័ន្ធនឹងសាក្សីដែលភាគីផ្សេងបានស្នើសុំនោះទេ*"[2]។ ហេតុនេះ មេធាវីការពារក្តីមិន "អាចរកបាន" អត្ថបទនេះ មុនពេលបើកការជំនុំជម្រះទៅតាមអត្ថន័យដែលមានចែងក្នុងវិធាន ៨៧(៤) ទេ[3]។

៦. ការមិនបញ្ចូលអត្ថបទនេះដោយផ្អែកលើបញ្ហាបច្ចេកទេស ដូចជាករណីដែលមេធាវីការពារក្តីមិនបានដាក់អត្ថបទនេះនៅក្នុងបញ្ជីឯកសាររបស់ខ្លួនមុនពេលបើកការជំនុំជម្រះនោះ នឹងជាការផ្ទុយទៅនឹងការស្វែងរកការពិតរបស់អង្គជំនុំជម្រះសាលាដំបូង។ អត្ថបទនេះត្រូវតែបានដាក់បញ្ចូលដោយសារ កាលពីជាង ១ ឆ្នាំមុន នៅពេលដែលមេធាវីការពារក្តីបានដាក់បញ្ជីឯកសាររបស់ខ្លួន

---

[2] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីដែលមានចំណងជើងថា៖ "ការឆ្លើយតបទៅនឹងសំណួរនានាដែលបានសួរក្នុងពេលប្រជុំរៀបចំសវនាការ" ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ (គូសបញ្ជាក់បន្ថែម)។

[3] ដោយពិចារណាលើយុត្តិសាស្ត្ររបស់តុលាការ ICTY និង ICTR អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "សញ្ញាណនៃ "ការអាចរកបាន" នៃភស្តុតាង មានទំនាក់ទំនងនឹងការបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដ", សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២, ឯកសារ E190, កថាខណ្ឌ ២៣។

សម្រាប់ការជំនុំជម្រះក្តី អត្ថិភាព និងភាពពាក់ព័ន្ធរបស់អត្ថបទនេះមិនទាន់ត្រូវបានមើលឃើញទេ ជាពិសេសដោយពិចារណាថា ភាគីបានទទួលការជូនដំណឹងថា ពួកគេពុំចាំបាច់ដាក់បញ្ជីឯកសារដែលពាក់ព័ន្ធនឹងសាក្សីដែលភាគីផ្សេងបានស្នើសុំឡើយ។ ពុំមានភាគីណាមួយនឹងត្រូវបាត់បង់ប្រយោជន៍ដោយសារមេធាវីការពារក្តីប្រើប្រាស់អត្ថបទនេះ នៅពេលសវនាការទេ ដោយហេតុថា ភាគីទាំងអស់នៅមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងវាយតម្លៃអត្ថបទសង្ខេបនេះ[4] មុនពេលលោក Short មកផ្តល់សក្ខីកម្ម។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំដាក់អត្ថបទដែលនិពន្ធដោយលោក Philip Short មានចំណងជើងថា *Devil's Advocate: There Should be no KR Trial* (*ការតស៊ូមតិរបស់ក្រុមបីសាច៖ មិនគួរមានតុលាការកាត់ទោសខ្មែរក្រហម*) នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងស្នើសុំឱកាសបានប្រើប្រាស់អត្ថបទនេះក្នុងពេលសួរដេញដោលលោក Short។

សូមលោក លោកស្រីចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| | |
|---|---|
| ______________ | ________________ |
| អាង ឧត្តម | Michael G. KARNAVAS |

សហមេធាវីការពារក្តីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានា**ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២**

[4] សហព្រះរាជអាជ្ញារងអន្តរជាតិលោក William Smith បានយល់ស្របថា សម្ភារៈឯកសារមិនគួរត្រូវបានបដិសេធ ដោយសារតែឯកសារនោះមិនអាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង មុនពេលចាប់ផ្តើមការជំនុំជម្រះនោះទេ។ គាត់បានថ្លែងនៅក្នុងសវនាការថា៖ "លោកប្រធាន យើងខ្ញុំយល់ស្របដែរថា មានកាលៈទេសៈមួយចំនួនដែលនឹងអាចកើតមានឡើងនៅពេលដែលឯកសារណាមួយ វាមានសារៈសំខាន់នៅពេលក្រោយៗមកទៀត ទាក់ទងទៅនឹងការវិនិច្ឆ័យភាពជឿជាក់បានរបស់សាក្សី។ យើងខ្ញុំមិនស្នើសុំថា គ្រប់ឯកសារទាំងអស់ត្រូវតែដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះទេ"។ ប្រតិចារឹកនៃការជំនុំជម្រះក្តី ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៥១ (ភាសាអង់គ្លេស)។